ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១១ ន.ស ៩៤

# ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិវង្ស
អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើនៅថ្ងៃទី២៤.៩.១៩៩៣
បានទ្រង់យល់ព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១.១១.១៩៩៣
គណៈរដ្ឋមន្ត្រីបានយល់ព្រមផង

## ប្រកាសឱ្យប្រើ

ច្បាប់ដែលអនុម័តដោយរដ្ឋសភា នាថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ១៩៩៤ ស្តីពីច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដូចមានសេចក្តីតទៅនេះ :

បណ្តាចំណូលផ្សេងៗទៀតនឹងត្រូវបានបង់បញ្ចូលអាស្រ័យដោយអំណាចនៃវត្ថុបទនីតិ-
បញ្ញត្តិ ឬបទបញ្ជា ។

# ភាគទី ១
# ការរៀបចំច្បាប់ហិរញ្ញវត្ថុ

## ជំពូកទី ១
## បទបញ្ញត្តិទូទៅ

មាត្រា ១.-

មាត្រា ៧.-

## ជំពូកទី ២
## បទបញ្ញត្តិនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ

មាត្រា ៨.-

## ជំពូកទី ៣
## បទបញ្ញត្តិទាំងឡាយស្តីពីពន្ធ និងអាករដែលប្រមូលដោយអង្គភាពពន្ធ

### ផ្នែកទី ១
### បទបញ្ញត្តិស្តីពីសារពើពន្ធ

#### I - ពន្ធលើប្រាក់បៀវត្ស

មាត្រា ៩.-

មាត្រា ១០.-

## II- ពន្ធលើប្រាក់ចំណេញ

មាត្រា ២៥.-

-----------------------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------------------

-----------------------------------------------------------------------------------------------------------

## III- ពន្ធលើដីធ្លីមិនបានប្រើប្រាស់

មាត្រា ២៦.-

ត្រូវបានបង្កើតពន្ធដីធ្លីលើដីមិនបានប្រើប្រាស់ ដើម្បីជាប្រយោជន៍ថវិកាជាតិ ។

មាត្រា ២៧.-

ពន្ធនេះកំណត់លើដីដែលគ្មានសំណង់ និងដីដែលមានសំណង់បោះបង់ស្ថិតក្នុងទីក្រុងនានា និងក្នុងតំបន់ទាំងឡាយ ដែលកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ ។

មាត្រា ២៨.-

ត្រូវបានបង្កើតគណៈកម្មការមួយហៅថា គណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ ដែលមានសមាសភាពកំណត់ដោយអនុក្រឹត្យ ។

គណៈកម្មការនេះមានភារកិច្ច ៖

- បង្កើតបញ្ជីរាយឈ្មោះទីក្រុង និងតំបន់ដែលមានដីត្រូវជាប់ពន្ធ
- កំណត់ប្រចាំឆ្នាំនូវតម្លៃដីក្នុង ១ ម៉ែត្រក្រឡា
- ផ្តល់មតិចំពោះរឿងវិវាទ

មាត្រា ២៩.-

ពន្ធដីធ្លីលើដីមិនបានប្រើប្រាស់ ត្រូវបង់ដោយកម្មសិទ្ធិករ ។

មាត្រា ៣០.-

មូលដ្ឋានកំណត់ពន្ធគឺជាថ្លៃដីគិតតាមថ្លៃទីផ្សារតាមទីក្រុងនិងតាមតំបន់នីមួយៗដែលវាយតម្លៃទៅតាមតម្លៃគិតក្នុងមួយម៉ែត្រក្រឡា កំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ យ៉ាងយឺតបំផុតនៅថ្ងៃទី ៣០ ខែ មិថុនានៃឆ្នាំប្រមូលពន្ធ ។ ក្នុងការគិតពន្ធត្រូវបានអនុញ្ញាតឱ្យកាត់ចេញពីមូលដ្ឋានកំណត់ពន្ធចំនួន ១.២០០ ម៉ែត្រក្រឡា ក្នុងដីមួយកន្លែង ។

មាត្រា ៣១.-

ពន្ធនេះត្រូវកំណត់តាមអត្រា ២% លើមូលដ្ឋានកំណត់ពន្ធដែលបានចែងក្នុងមាត្រា ៣០ ។

មាត្រា ៣២.-

កម្មសិទ្ធិករនៃដីធ្លីជាប់ពន្ធមានភារកិច្ចត្រូវគណនាប្រាក់ពន្ធតាមទម្រង់លិខិតប្រកាសផ្តល់ដោយរដ្ឋបាលពន្ធនិងត្រូវបង់ពន្ធនេះយ៉ាងយឺតបំផុតនៅថ្ងៃទី ៣០ ខែ កញ្ញា នៃឆ្នាំនីមួយៗ ជូនទៅផ្នែកពន្ធនៅកន្លែងដែលដីធ្លីជាប់ពន្ធស្ថិតនៅ ។ ដីធ្លីជាប់ពន្ធនីមួយៗ ត្រូវធ្វើលិខិតប្រកាស ១ ច្បាប់ ។

មាត្រា ៣៣.-

ការត្រួតពិនិត្យមូលដ្ឋានកំណត់ពន្ធនិងការត្រួតពិនិត្យការបង់ពន្ធ គឺជាសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ៣៤.-

ក្នុងករណីដែលពុំបានគោរពបទបញ្ញត្តិនៃមាត្រា ៣៣ ទណ្ឌកម្មដែលអនុវត្តគឺជាទណ្ឌកម្មដែលបានចែងក្នុងមាត្រា ៥៧.៥៩ និង ៦០ នៃច្បាប់ចុះថ្ងៃទី ២៨ ខែ ធ្នូ ១៩៩៣ ស្តីពីហិរញ្ញវត្ថុសម្រាប់ ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០២ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។

មាត្រា ៣៥.-

នីតិវិធីធម្មតានៃការកំណត់ឡើងវិញនូវពន្ធដែលកំណត់មិនបានត្រឹមត្រូវក្រោយពីការត្រួតពិនិត្យ គឺជានីតិវិធីដែលបានចែងក្នុងមាត្រា ២៤ នៃច្បាប់ដូចមានចែងក្នុងមាត្រាខាងលើ ។

មាត្រា ៣៦.-

នីតិវិធីនៃការកំណត់ពន្ធជាឯកតោភាគីរបស់រដ្ឋការពន្ធដារត្រូវអនុវត្តធ្វើក្នុងករណីបានចែងក្នុងមាត្រា ៥៨ នៃច្បាប់ខាងលើដែរ ។

## IV- អាករលើជ័យលាភ

មាត្រា ៣៧.-

-------------------------------------------------------------------------------------------

-------------------------------------------------------------------------------------------

-------------------------------------------------------------------------------------------

មាត្រា ៣៨.-

-------------------------------------------------------------------------------------------

-------------------------------------------------------------------------------------------

-------------------------------------------------------------------------------------------

## V-ពន្ធប៉ាតង់

មាត្រា ៣៩.-

ចំនួនប្រាក់ពន្ធប៉ាតង់ដែលបានកំណត់ទុកក្នុងក្រឹត្យច្បាប់លេខ ២២ ក្រ.ច ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៨៥ ត្រូវបានកែប្រែនិងជំនួសដោយចំនួនប្រាក់ពន្ធដូចមានចែងក្នុងតារាងខាងក្រោម ៖

| ថ្នាក់ជាតិ | ផលរបរប្រចាំឆ្នាំ | | ចំនួនប្រាក់ពន្ធជាតិប្រចាំឆ្នាំ |
|---|---|---|---|
| | សកម្មភាពពាណិជ្ជកម្ម ឧស្សាហកម្ម | សកម្មភាពសេវាកម្មលើកលែងតែ ផ្ទះសំណាក់ហូបចុក និងភោជនីយដ្ឋាន | |
| ១ | ដល់ ៧.៥០០.០០០៛ | ដល់ ៣.០០០.០០០៛ | ១៥.០០០៛ |
| ២ | ពី ៧.៥០០.០០១- ១២.៥០០.០០០៛ | ពី ៣.០០០.០០១- ៥.០០០.០០០៛ | ២១.០០០៛ |
| ៣ | - ១២.៥០០.០០១- ២៤.០០០.០០០៛ | - ៥.០០០.០០១- ១០.០០០.០០០៛ | ២៧.០០០៛ |
| ៤ | - ២៤.០០០.០០១- ៣០.០០០.០០០៛ | - ១០.០០០.០០១- ១២.០០០.០០០៛ | ៤០.០០០៛ |
| ៥ | - ៣០.០០០.០០១- ៣៧.៥០០.០០០៛ | - ១២.០០០.០០១- ១៥.០០០.០០០៛ | ៦០.០០០៛ |
| ៦ | - ៣៧.៥០០.០០១- ៥០.០០០.០០០៛ | - ១៥.០០០.០០១- ២០.០០០.០០០៛ | ៩០.០០០៛ |
| ៧ | - ៥០.០០០.០០១- ៦២.០០០.០០០៛ | - ២០.០០០.០០១- ២៤.៨០០.០០០៛ | ១៤០.០០០៛ |
| ៨ | - ៦២.០០០.០០១- ៧៥.០០០.០០០៛ | - ២៤.៨០០.០០១- ៣០.០០០.០០០៛ | ១៨០.០០០៛ |
| ៩ | - ៧៥.០០០.០០១- ១០០.០០០.០០០៛ | - ៣០.០០០.០០១- ៤០.០០០.០០០៛ | ២៤០.០០០៛ |
| ១០ | - ១០០.០០០.០០១- ១០០០.០០០.០០០៛ ជាគនិមាត្រូវបង់បន្ថែម ១ ភាគពាន់ | - ៤០.០០០.០០១- ៤០០.០០០.០០០៛ ជាគនិមាត្រូវបង់បន្ថែម ២.៥ ភាគពាន់ | |

## VI- ពន្ធប្រថាប់ត្រា

**មាត្រា ៤០.-**

១- ពន្ធប្រថាប់ត្រាត្រូវកំណត់តាមអត្រាសមាមាត្រ ៤% ចំពោះការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ ឬការផ្ទេរសិទ្ធិកាន់កាប់ដីដែលគ្មានសំណាក់ក្រោមរូបភាពជា ការលក់ ការដោះដូរ ការទទួលអំណោយ ការដាក់ភាគហ៊ុនក្នុងក្រុមហ៊ុន ។

២- ត្រូវជាប់ពន្ធប្រថាប់ត្រាតាមអត្រាសមាមាត្រ ៤% ចំពោះការផ្ទេរកម្មសិទ្ធិមធ្យោបាយដឹកជញ្ជូននិងយានជំនិះដូចខាងក្រោម ៖

- រថយន្តដឹកទំនិញធុនធ្ងន់ រថយន្តដឹកទំនិញធុនស្រាល រថយន្ត ទោចក្រយានយន្ត
- កាណូត សាឡង់ កប៉ាល់

៣- លិខិតមានលក្ខណៈគតិយុត្តដូចខាងក្រោម ត្រូវជាប់ពន្ធប្រថាប់ត្រា ៖

- លិខិតស្តីពីការបង្កើតក្រុមហ៊ុន ១០០.០០០ រៀល
- លិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ១០០.០០០ រៀល
- លិខិតស្តីពីការរំលាយក្រុមហ៊ុន ១០០.០០០ រៀល
- កិច្ចសន្យាផ្គត់ផ្គង់សេវា ឬសម្ភារៈទំនិញដល់អង្គភាពសាធារណៈ ១០០.០០០ រៀល

**មាត្រា ៤១.-**

ពន្ធប្រថាប់ត្រាត្រូវបានបង់ដោយអ្នកទទួលកម្មសិទ្ធិ ឬទទួលសិទ្ធិកាន់កាប់ដីធ្លីដែលគ្មានសំណាក់ គិតជាសមាមាត្រលើតម្លៃពិតប្រាកដនៃទ្រព្យសម្បត្តិនាថ្ងៃផ្ទេរកម្មសិទ្ធិនិងសិទ្ធិកាន់កាប់ ។ ប៉ុន្តែដើម្បីឱ្យមានភាពងាយស្រួលរួមបញ្ចូលក្រសួង

សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចកំណត់តម្លៃសម្រាប់រយៈកាលនីមួយៗ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការគិតប្រាក់ពន្ធដែលត្រូវបង់ ។

មាត្រា ៤២.-

ប្រតិបត្តិការទាំងឡាយស្តីពីការផ្ទេរកម្មសិទ្ធិ ផ្ទេរសិទ្ធិកាន់កាប់និងលិខិតមានលក្ខណៈគតិយុត្តិដែលជាប់ពន្ធប្រថាប់ត្រា ត្រូវប្រថាប់ត្រាក្នុងកំឡុងពេល ៣ ខែ ចាប់ពីថ្ងៃដែលប្រតិបត្តិការកើតឡើង ។ ហួសរយៈពេលនេះត្រូវពិន័យស្មើនឹងចំនួនប្រាក់ពន្ធប្រថាប់ត្រាដែលត្រូវបង់ ។

មាត្រា ៤៣.-

ហាមភ្នាក់ងាររាជការមានសមត្ថកិច្ចផ្តល់វិញ្ញាបនប័ត្រថ្មីសំគាល់កម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ប្រើប្រាស់កម្មសិទ្ធិឬអ្នកកាន់កាប់ថ្មីនោះមិនបានបង់ពន្ធប្រថាប់ត្រា ។

មាត្រា ៤៤.-

របបបទអនុវត្តបញ្ញត្តិទាំងឡាយដែលចែងអំពីពន្ធប្រថាប់ត្រា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ៤៥.-

ច្បាប់ស្តីពីការបង្កើតពន្ធប្រថាប់ត្រាដែលបានប្រកាសឱ្យប្រើដោយក្រឹត្យលេខ ២១ ក្រ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ១៩៩១ ត្រូវបានកែប្រែដោយបទបញ្ញត្តិទាំងឡាយនៃផ្នែកនេះ ។

## VII-ពន្ធតែមប្រ៍

មាត្រា ៤៦.-

ពន្ធតែមប្រ៍ កំណត់លើលិខិតរដ្ឋបាល លិខិតធនាគារ លិខិតក្រៅធនាគារ និងលើប័ណ្ណប្រកាស ។ រាជរដ្ឋាភិបាលកំណត់វិធានអនុវត្ត និងតារាងពន្ធតែមប្រ៍ ដោយអនុក្រឹត្យ ។ ហាមភ្នាក់ងាររាជការមានសមត្ថកិច្ចទទួល ឬចេញលិខិតត្រូវជាប់ពន្ធតែមប្រ៍ ដែលមិនទាន់បានបង់ពន្ធ ។

មាត្រា ៤៧.-

ពន្ធតែមប្រ៍ ត្រូវបង់តាមការបិទសន្លឹកតែមប្រ៍ ឬតាមការបង់ប្រាក់ផ្ទាល់ដោយចេញបង្កាន់ដៃ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកំណត់របបបទ និងលក្ខខណ្ឌអនុវត្តការប្រមូលពន្ធតែមប្រ៍ ដោយប្រកាស ។

មាត្រា ៤៨.-

សន្លឹកតែមប្រ៍ នីមួយៗមានតម្លៃ ១០០ រៀល ២០០រៀល ៥០០ រៀល ១.០០០ រៀល ២ ០០០ រៀល ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាអង្គការមានសមត្ថកិច្ចតែមួយគត់ក្នុងការធ្វើការបោះពុម្ពសន្លឹកតែមប្រ៍ ។

មាត្រា ៤៩.-

ច្បាប់ស្តីពីការបង្កើតតែមប្រ៍ សារពើពន្ធ ដែលបានប្រកាសឱ្យប្រើដោយក្រឹត្យលេខ ២៣ ក្រ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ១៩៩១ ត្រូវបានកែប្រែដោយបទបញ្ញត្តិនៃផ្នែកនេះ ។

## ផ្នែកទី ២

## បទបញ្ញត្តិស្តីពី សកម្មភាពត្រួតពិនិត្យ ការប្រមូលចំណូល និងបណ្តឹង

### I- អត្តសញ្ញាណកម្មសហគ្រាស ដែលជាប់ពន្ធតាមរបបពិតប្រាកដ

មាត្រា ៤០.-

សហគ្រាសជាប់ពន្ធតាមរបបពិតប្រាកដ ដែលត្រូវកាន់បញ្ជីគណនេយ្យតាមប្លង់គណនេយ្យទូទៅនៃព្រះរាជាណាចក្រកម្ពុជា ត្រូវចុះបញ្ជីនៅនាយកដ្ឋានពន្ធដារ និងត្រូវបានអង្គការនេះផ្តល់លេខអត្តសញ្ញាណកម្មសារពើពន្ធតែមួយគត់ដែលមានលក្ខណៈជាអចិន្ត្រៃយ៍ មិនប្រែប្រួលរហូតដល់ពេលសហគ្រាសឈប់ធ្វើសកម្មភាពជាស្ថាពរ ។

មាត្រា ៤១.-

លេខអត្តសញ្ញាណកម្មសារពើពន្ធដែលនាយកដ្ឋានពន្ធដារបានផ្តល់ឱ្យនេះ គឺជាលេខសំគាល់តែមួយគត់របស់សហគ្រាស ទោះបីសហគ្រាសមានគ្រឹះស្ថានអាជីវកម្មដោយឡែកៗច្រើនក៏ដោយ ។ លេខនេះត្រូវប្រើប្រាស់ដោយគ្រប់នាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ នាយកដ្ឋានពន្ធដារគឺជាអង្គការមានសមត្ថកិច្ចតែមួយគត់ក្នុងការផ្តល់លេខអត្តសញ្ញាណកម្មសារពើពន្ធ និងជាអ្នកបញ្ជូនលេខនេះទៅផ្នែកទាំងឡាយនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ៤២.-

សហគ្រាសទាំងឡាយដែលបានទទួលលេខអត្តសញ្ញាណកម្មសារពើពន្ធ មានកាតព្វកិច្ចត្រូវចុះលេខអត្ត-សញ្ញាណកម្មនេះនៅលើឯកសារផ្លូវការគ្រប់ប្រភេទ ដូចជាប្រកាសសារពើពន្ធ ប្រតិវេទន៍ពន្ធ ព្រមទាំងឯកសារគ្រប់ប្រភេទដែលមានលក្ខណៈពាណិជ្ជកម្មដូចជា វិក្កយបត្រ វិក្កយបត្រជាទម្រង់ បញ្ជីកំណត់តម្លៃ ពាក្យសុំដេញថ្លៃផ្គត់ផ្គង់សេវាឬសម្ភារៈទំនិញដល់អង្គការសាធារណៈ ។

មាត្រា ៤៣.-

១- សហគ្រាសដែលជាប់ពន្ធតាមរបបពិតប្រាកដ មានភារកិច្ចត្រូវបង្កើត និងប្រើប្រាស់វិក្កយបត្រ ។

២- រាល់វិក្កយបត្រដែលពុំមានចុះលេខអត្តសញ្ញាណកម្មសារពើពន្ធរបស់សហគ្រាសដែលជាអ្នកចេញវិក្កយបត្រ មិនត្រូវបានអនុញ្ញាតឱ្យយកមកគិតគូរសម្រាប់គណនាលទ្ធផលសារពើពន្ធរបស់សហគ្រាសដែលជាអ្នកទទួលវិក្កយបត្រ ហើយនិងជាអ្នកដែលត្រូវជាប់ពន្ធលើប្រាក់ចំណេញឡើយ ។

### II- សហគ្រាសដែលជាប់អាករលើផលរបរតាមរបបទៅការ

មាត្រា៤៤.-

សហគ្រាសជាប់អាករលើរបបទៅការ ដែលមានផលរបរជាប់ពន្ធក្នុងឆ្នាំ ១៩៩៤ តាមបញ្ជីពន្ធរបស់អង្គការពន្ធ មានចំនួនលើសពី ១០.០០០.០០០ រៀល មានកាតព្វកិច្ចដូចតទៅ ៖

១- ត្រូវកាន់បញ្ជីចំណូលភ្ជាប់ដោយវិក្កយបត្រ ដើម្បីកំណត់ផលរបររបស់ខ្លួន ។ គ្រប់ទំព័រនៃបញ្ជីចំណូលត្រូវតែមានចុះលេខនិងចុះហត្ថលេខាបញ្ជាក់ជាមុនដោយអង្គការពន្ធ ។ បញ្ជីនេះត្រូវកត់ត្រាគ្រប់ប្រតិបត្តិការដែលសម្រេចបានប្រចាំថ្ងៃនីមួយៗ ។ ប៉ុន្តែរាល់ប្រតិបត្តិការដែលបានទទួលសាច់ប្រាក់មិនលើសពីដែលមានតម្លៃក្រោម ១០០.០០០ រៀល បានមកពីការលក់រាយ ឬផ្គត់ផ្គង់សេវាឱ្យអតិថិជន ឯកជនអាចអនុញ្ញាតឱ្យចុះបញ្ជីជាសរុបនៅពេលចុងថ្ងៃនីមួយៗ ។

២- សហគ្រាសដែលមានសកម្មភាពលក់ទំនិញក្នុងសភាពដើម ឬផលិតផលដែលផលិតបានត្រូវកាន់បន្ថែមនូវបញ្ជីកត់ត្រាការទិញ ភ្ជាប់ដោយវិក្កយបត្រ និងសក្ខីប័ត្រនានា ។

៣- ត្រូវបង្ហាញបញ្ជីនិងសក្ខីប័ត្រនានាដល់អង្គការពន្ធនៅរាល់ពេលដែលអង្គការនេះស្នើសុំ។ បើមិនបង្ហាញទេនោះ អ្នកប្រព្រឹត្តល្មើសនឹងត្រូវរងការកំណត់ពន្ធជាឯកតោភាគី ។

## III-ការប្រមូលប្រាក់ពន្ធដែលមិនបានបង់

មាត្រា ៥៥.-

ការប្រមូលពន្ធនិងប្រាក់អាករគឺជាសមត្ថកិច្ចរបស់អង្គការពន្ធ ដែលទទួលបន្ទុកផងដែរក្នុងការកំណត់មូលដ្ឋានជាប់ពន្ធ គណនាប្រាក់ពន្ធ និងត្រួតពិនិត្យពន្ធនិងអាករ ។

មាត្រា ៥៦.-

ប្រាក់ពន្ធ និងប្រាក់អាករដែលត្រូវបង់ព្រមទាំងប្រាក់ពិន័យដែលបានអនុវត្តបង្កើតបានជាតារាងស្ថានភាពប្រមូលពន្ធសម្រាប់ផ្តល់ជូនទៅផ្នែកទារបំណុលពន្ធនៃអង្គការពន្ធ ។ ប្រាក់ពន្ធដែលបានគិតរួចហើយត្រូវទារភ្លាម ។

មាត្រា ៥៧.-

បំណុលសារពើពន្ធដែលត្រូវទារគឺជាកម្មវត្ថុនៃលិខិតជូនដំណឹងទារផ្ញើឱ្យអ្នកជំពាក់ប្រាក់ពន្ធដែលអាចជាប្រធានសហគ្រាសឯកត្តជន ឬជានីតិបុគ្គលដែលពាក់ព័ន្ធ ឬជាអ្នកជំពាក់ប្រាក់ពន្ធដទៃទៀតដែលត្រូវបង់ពន្ធ ឬអាករ ។

មាត្រា ៥៨.-

ការមិនបានបង់ប្រាក់ពន្ធ ប្រាក់អាករ ឬប្រាក់ពិន័យក្នុងកំឡុងពេលមួយខែ គិតពីថ្ងៃទទួលលិខិតជូនដំណឹងទារ ផ្នែកទារបំណុលពន្ធ ត្រូវផ្ញើលិខិតរំលឹកមុនការចាប់ផ្តើមនីតិវិធានការតឹងទារ។ លិខិតរំលឹកនេះផ្តល់រយៈពេលចំនួន១៥ថ្ងៃ គិត ពីថ្ងៃដែលបានទទួលលិខិតជូនដំណឹងដើម្បីទុកឱ្យអ្នកជំពាក់ពន្ធទូទាត់បំណុលសារពើពន្ធ។ ចំនួនប្រាក់ដែលត្រូវបង់ក្នុងឱកាសរំលឹកនេះត្រូវបន្ថែមចំនួន ១០% ជាប្រាក់ពិន័យ ។

មាត្រា ៥៩.-

ហួសរយៈពេលរំលឹកខាងលើ ផ្នែកទារបំណុលពន្ធត្រូវចាប់ផ្តើមអនុវត្តវិធានការតឹងទារ ។ ក្នុងករណីអនុវត្តវិធានការខាងលើ អាជ្ញាធរមូលដ្ឋាននានា និងអង្គការធនាគារមានកាតព្វកិច្ចជួយអង្គការពន្ធដារ ក្នុងពេលអង្គការនេះស្នើសុំ ។

មាត្រា ៦០.-

វិធានការតឹងទារបំណុលពន្ធមានពីរកម្រិត ៖

កម្រិតទី ១: ការរឹបអូសឈរវត្ថុ ឬអចលនវត្ថុ បិទជាបណ្តោះអាសន្ន ឬជាស្ថាពរនូវគ្រឹះស្ថានវិជ្ជាជីវៈដូចជា ឃ្លាំង ឃ្លាំងទំនិញ កន្លែងផលិត ការិយាល័យ រោងជាង ។

ករណីទី ២: ការលក់ចលនវត្ថុ ឬ អចលនវត្ថុ ។ អ្នកជាប់ពន្ធអាចប្តឹងជំទាស់ទៅតុលាការរដ្ឋប្បវេណី អំពីការអនុវត្តន៍មិនបានត្រឹមត្រូវនូវវិធានការតឹងទារនៃផ្នែកទារបំណុលពន្ធ ។

មាត្រា ៦១.-

វិធានការតឹងទារត្រូវកត់ត្រាឱ្យច្បាស់ក្នុងកំណត់ហេតុដែលធ្វើឡើងដោយផ្នែកទារបំណុលពន្ធ ។

មាត្រា ៦២.-

ការលក់ចលនវត្ថុ ឬអចលនវត្ថុទាំងឡាយអាចអនុវត្តទៅបាន ដរាបណាមានការអនុញ្ញាតពិសេសពីនាយផ្នែកសារពើពន្ធដែលមានសមត្ថកិច្ច តាមសំណើរបស់អ្នកទទួលខុសត្រូវក្នុងការទារបំណុលពន្ធ ។

មាត្រា ៦៣.-

ការលក់អាចប្រព្រឹត្តទៅបានក្រោយរយៈពេលមួយខែ គិតចាប់ពីពេលបង្កើតកំណត់ហេតុនៃការអនុវត្តវិធានការតឹងទារករណីទី ១ ។ ការលក់ត្រូវប្រព្រឹត្តតាមបែបបទដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៦៤.-

ការដាក់ពាក្យសុំដោះស្រាយវិវាទដោយអ្នកជាប់ពន្ធ ឬតតិយជនក្នុងរយៈពេលកំណត់ដែលបានចែងក្នុងមាត្រាខាងលើ សំដៅតវ៉ាឬស្នើបន្ធូរបន្ថយប្រាក់ពន្ធនោះពុំមានឥទ្ធិពលផ្អាកការទារពន្ធនិងផ្អាកការអនុវត្តវិធានការតឹងទារនោះឡើយ ។

មាត្រា ៦៥.-

អំពើប្រមាថនិងអំពើហិង្សាទាំងឡាយ ប្រព្រឹត្តចំពោះភ្នាក់ងារដែលកំពុងអនុវត្តវិធានការតឹងទារព្រមទាំងរាល់អំពើប្រឆាំងផ្សេងទៀត គឺជាកម្មវត្ថុនៃការធ្វើកំណត់ហេតុ ។ អ្នកប្រព្រឹត្តអំពើទាំងនេះជាកម្មវត្ថុនៃបណ្តឹងព្រហ្មទណ្ឌ ដែលស្នើឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## IV ទិដ្ឋភាពផ្សេងៗដែលទាក់ទងដល់ការទារបំណុលពន្ធ

មាត្រា ៦៦.-

តតិយជនអ្នកកាន់កាប់ប្រាក់របស់អ្នកជាប់ពន្ធអាស្រ័យនឹងពិន័យនៅពេលដែលមានសំណើដោយលិខិតជូនដំណឹងរបស់អគ្គនាយកពន្ធ មានភារៈត្រូវបង់ជំនួសអ្នកជាប់ពន្ធនូវប្រាក់ពន្ធ ប្រាក់អាករ និងប្រាក់ពិន័យដែលអ្នកជាប់ពន្ធត្រូវបង់ដោយប្រើប្រាស់មូលនិធិដែលខ្លួនបានកាន់កាប់នោះ ។ នីតិវិធីនៃការជូនដំណឹងចំពោះតតិយជនអ្នកកាន់កាប់ប្រាក់របស់អ្នកជាប់ពន្ធ ត្រូវយកមកអនុវត្តដូចគ្នាចំពោះតតិយជនដែលជាកូនបំណុលរបស់អ្នកជាប់ពន្ធ ។

មាត្រា ៦៧.-

ចាប់តាំងពីពេលដែលបានទទួលលិខិតជូនដំណឹង តតិយជនអ្នកកាន់កាប់ប្រាក់របស់អ្នកជាប់ពន្ធត្រូវប្រើប្រាស់ប្រាក់របស់អ្នកជាប់ពន្ធដែលខ្លួនបានកាន់កាប់នោះ សម្រាប់សងជាអាទិភាពនូវប្រាក់ពន្ធដែលត្រូវបង់ ។

មាត្រា ៦៨.-

តតិយជន អ្នកកាន់កាប់ប្រាក់របស់អ្នកជំពាក់ពន្ធ ដែលមិនបានសងប្រាក់ពន្ធតាមសំណើរបស់ផ្នែកទារបំណុលពន្ធ ត្រូវទទួលខុសត្រូវដោយខ្លួនឯងក្នុងការយកទ្រព្យសម្បត្តិផ្ទាល់ខ្លួនមកបង់ពន្ធ អាករនិងពិន័យដូចគ្នានឹងអ្នកជំពាក់ប្រាក់ពន្ធខាងលើដែរ ។

មាត្រា ៦៩.-

ក្រោយពេលបញ្ជូនលិខិតជូនដំណឹងចំពោះតតិយជនអ្នកកាន់កាប់ប្រាក់របស់អ្នកជំពាក់ពន្ធ ប្រសិនបើអ្នកជំពាក់ពន្ធបានសងប្រាក់ពន្ធ ដែលត្រូវបង់នោះរួចហើយ ផ្នែកទារបំណុលពន្ធត្រូវជូនដំណឹងវិញភ្លាមស្តីពីមោឃភាពនៃលិខិតជូនដំណឹងដែលខ្លួនបានផ្ញើដល់តតិយជនអ្នកកាន់កាប់ប្រាក់របស់អ្នកជំពាក់ពន្ធ ។

មាត្រា ៧០.-

អ្នកដែលទទួលមរតកឬអ្នកដែលទទួលអំណោយ មានភារកិច្ចត្រូវសងប្រាក់ពន្ធនិងប្រាក់ពិន័យដែលត្រូវបង់ដោយមរណជន ឬអ្នកផ្តល់អំណោយរហូតដល់គ្រប់ចំនួនទឹកប្រាក់ដែលខ្លួនបានទទួល ។

មាត្រា ៧១.-

ក្នុងករណីលក់មូលនិធិពាណិជ្ជកម្ម សហគ្រាស អសង្ហារឹម អ្នកទិញនិងអ្នកលក់ត្រូវទទួលខុសត្រូវរួមគ្នាក្នុងការសងប្រាក់ពន្ធនិងប្រាក់ពិន័យដែលត្រូវបង់ដោយអ្នកលក់នាពេលលក់ រហូតដល់គ្រប់ចំនួនទឹកប្រាក់ថ្លៃលក់ធម្មតា ។

មាត្រា ៧២.-

អ្នកដឹកនាំសហគ្រាស ដែលបានប្រើប្រាស់ល្បិចបន្លំពន្ធ ឬបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរនិងម្តងទៀតចំពោះកាតព្វកិច្ចសារពើពន្ធនៃសហគ្រាស ត្រូវទទួលខុសត្រូវខាងហិរញ្ញវត្ថុក្នុងការសងប្រាក់ពន្ធនិងប្រាក់ពិន័យដែលត្រូវបង់ដោយសហគ្រាស ។

មាត្រា ៧៣.-

ការបង្ខំលើរូបកាយដើម្បីប្រមូលប្រាក់ពន្ធ ប្រាក់អាករនិងប្រាក់ពិន័យដែលត្រូវបង់ ត្រូវស្នើដោយប្រធានផ្នែកសារពើពន្ធមានសមត្ថកិច្ច ។

ការបង្ខំលើរូបកាយ អាចអនុវត្តបានតែក្នុងក្របខ័ណ្ឌដែលមានសេចក្តីសម្រេចរបស់តុលាការ ។

## V- អាជ្ញាយុកាលនៃការទារចំណុលពន្ធ

មាត្រា ៧៤.-

ការបញ្ជូនចេញនូវលិខិតជូនដំណឹងទារបំណុលពន្ធ បញ្ឈប់នូវអាជ្ញាយុកាលដែលកំពុងប្រព្រឹត្តទៅហើយ បើកនូវរយៈពេលអាជ្ញាយុកាលថ្មីមួយទៀតមានចំនួន ៣ ឆ្នាំ ។

មាត្រា ៧៥.-

១- រយៈពេលនៃអាជ្ញាយុកាលដែលចែងក្នុងមាត្រាខាងលើ ដែលបានសំណាក់ពីការផុតអាជ្ញាយុកាលនៃការទារបំណុលពន្ធ ត្រូវបានពន្យារពេលវេលាដូចគ្នាចំពោះរាល់ការទទួលស្គាល់បំណុលដោយអ្នកជាប់ពន្ធនិងជាប់ពិន័យ ។

២- ក៏ត្រូវពន្យារពេលផុតឆ្នាំដែរចំពោះវិធានការបញ្ឈប់អាជ្ញាយុកាលទាំងឡាយ ដែលធ្វើឡើងដោយអង្គការពន្ធដូចជា ៖ ការបញ្ជូនលិខិតរំលឹក លិខិតជូនដំណឹងចំពោះតតិយជនអ្នកកាន់កាប់ប្រាក់របស់អ្នកជាប់ពន្ធ ឬការអនុវត្តវិធានការតឹងទារ ។

## VI- នីតិវិធាននៃការប្រមូលពន្ធ

មាត្រា ៤៦.-

១- ការតវ៉ាទាំងឡាយទាក់ទងដល់ការទារបំណុលពន្ធនិងពិន័យ ត្រូវធ្វើជាលាយលក្ខណ៍អក្សរផ្ញើមកផ្នែកទារបំណុលពន្ធ ក្នុងរយៈពេល ២ខែ ក្រោយពេលចេញសេចក្ដីជូនដំណឹងទារពន្ធ ។

២- ការតវ៉ាអាចប្រព្រឹត្តទៅបានចំពោះតែលើ ៖

ក- ការមិនគោរពតាមនីតិវិធីនៃការទារពន្ធដែលបានកំណត់

ខ- ចំនួនទឹកប្រាក់បំណុលសារពើពន្ធរួមទាំងការទូទាត់ទាំងឡាយ ដែលបានធ្វើរួចហើយ ។

មាត្រា ៤៧.-

ការតវ៉ាចំពោះការទារបំណុលពន្ធ អាចធ្វើឡើងដោយអ្នកជាប់ប្រាក់ពន្ធខ្លួនឯង អ្នកតំណាងស្របច្បាប់របស់ខ្លួន ឬដោយបុគ្គលទាំងឡាយដែលមានភារកិច្ចទទួលខុសត្រូវរួមគ្នាក្នុងការទូទាត់ប្រាក់ពន្ធ ។

មាត្រា ៤៨.-

១- ផ្នែកទារបំណុលពន្ធ មានរយៈពេល ៦ ខែ គិតពីពេលបានទទួលពាក្យដើម្បីឆ្លើយតបចំពោះបណ្ដឹងតវ៉ា

២- ហួសរយៈពេលនេះ បើពុំមានសេចក្ដីសម្រេចឆ្លើយតបណាមួយ ឬបើមានសេចក្ដីសម្រេចឆ្លើយតប ប៉ុន្តែមិនជាទីពេញចិត្តនៃអ្នកជាប់ប្រាក់ពន្ធ អ្នកជាប់ពន្ធមានរយៈពេល ២ ខែ ដើម្បីលើកយកវិវាទនេះប្ដឹងទៅតុលាការរដ្ឋប្បវេណី

៣- រយៈពេល ២ខែសម្រាប់ប្ដឹងទៅតុលាការត្រូវចាប់ផ្ដើម ៖

- ឬមួយពីពេលដែលអង្គការពន្ធបានបញ្ជូនសេចក្ដីសម្រេចលើសេចក្ដីតវ៉ា
- ឬមួយចាប់ពីផុតរយៈពេល ៦ ខែ ដែលទុកសម្រាប់ឱ្យអង្គការពន្ធដារចេញសេចក្ដីសម្រេច ។

## VII- ពន្ធដែលមិនអាចប្រមូលបាន

មាត្រា ៤៩.-

១- ផ្នែកទារបំណុលពន្ធអាចស្នើក្នុងរយៈពេល ២ ឆ្នាំ គិតចាប់ពីពេលដែលបានពិនិត្យ និងកត់ត្រាបំណុលពន្ធជាផ្លូវការ ចាត់ទុកជាប្រាក់ពន្ធមិនអាចប្រមូលបាននូវប្រាក់ពន្ធ និងប្រាក់ពិន័យដែលមិនបានទូទាត់កាលបើការប្រមូលពន្ធមិនអាចធ្វើបានដោយមូលហេតុការបាត់ខ្លួន ឬអសារធនភាពនៃអ្នកជាប់ពន្ធ ។

២- ផ្នែកទារបំណុលពន្ធត្រូវលើកហេតុផលឱ្យបានច្បាស់លាស់ បញ្ជាក់លើសំណើរបស់ខ្លួនអំពីពេលវេលាសមស្រប និងអំពីវិធានការចាត់ចែងនានា ដើម្បីទទួលនូវការទូទាត់ប្រាក់ពន្ធដែលត្រូវបង់ ។

៣- ការចាត់ជាបំណុលដែលមិនអាចទារបាន ពុំមានអានុភាពលុបចោលបំណុលសារពើពន្ធរបស់អ្នកជំពាក់ឡើយ ហើយការទារបំណុលពន្ធអាចអនុវត្តបានគ្រប់ពេល ក្នុងរយៈពេលនៃអាជ្ញាយុកាល ។

មាត្រា ៤០.-

សិទ្ធិសម្រេចលើសំណើចាត់ជាប្រាក់ពន្ធមិនអាចទារបាន ជាសមត្ថកិច្ចរបស់ ៖

១- ប្រធាននាយកដ្ឋានពន្ធដារ ឬតំណាងចំពោះបំណុលពន្ធតិចជាងឬស្មើនឹង ១០០០០០០០ រៀល

២- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំពោះបំណុលពន្ធលើសពី ១០.០០០.០០០ រៀល ។

## ជំពូកទី ៤

### I- បទបញ្ញត្តិស្ដីពីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

---------------------------------------------------------------------------------------

---------------------------------------------------------------------------------------

---------------------------------------------------------------------------------------

មាត្រា ៨៥.-

ប្រភពចំណូលដែលបានក្រោមចំណុចក្នុងប្រការបួនត្រូវបានប្រើប្រាស់សម្រាប់ ៖

- ការជំរះហិរញ្ញវត្ថុរបស់សហគ្រាសដែលមានទិសដៅសម្រាប់ផ្ទេរឱ្យទៅជាឯកជន
- ហិរញ្ញប្បទាននៃផ្នែកការកាត់បន្ថយចំនួនលើសបុគ្គលិករបស់សហគ្រាសសាធារណៈ
- ការផ្តល់ចាយជូនបានជាមូលធនជាគុណប្រយោជន៍របស់សហគ្រាសដែលស្ថិតនៅក្នុងវិស័យ សាធារណៈ ។

មាត្រា ៨៦.-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអាណាប័ករបស់គណនីនេះ ក្រោយពីបានឯកភាពពីគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

មាត្រា ៨៧.-

បទប្បញ្ញត្តិនៃច្បាប់ទាំងឡាយ ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៨៨.-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៩៤
ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជា
ប្រមុខរដ្ឋស្តីទី

ជា ស៊ីម

បានបង្គំទូលថ្វាយនិងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២
ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនីតិសម្បទា
និងអភិវឌ្ឍន៍និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច
និងហិរញ្ញវត្ថុ

គាត ឈន់

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

នរោត្តម រណឫទ្ធិ ហ៊ុន សែន